រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ :........................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ 1396

ថ្ងៃ 02.07.21

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** : របាយការណ៍លទ្ធផលនៃកិច្ចប្រជុំគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដឹកនាំដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** អំពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីព្រឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ Zoom។

ក្នុងកិច្ចប្រជុំគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៦ និងវិធានការសំខាន់ៗ ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងទប់ស្កាត់ការនាំចូលវីរុសបំប្លែងថ្មីប្រភេទ Delta ចូលក្នុងសហគមន៍កម្ពុជា ដោយសារវីរុសបំប្លែងថ្មីនេះ កំពុងឆ្លងរាលដាលនៅតាមប្រទេសជាច្រើនក្នុងពិភពលោក និងក្នុងតំបន់ រួមទាំងប្រទេសជិតខាងជាប់ប្រទេសកម្ពុជា។

យុទ្ធសាស្ត្រ និងវិធានការដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានណែនាំ មានដូចខាងក្រោម៖

– **យុទ្ធសាស្ត្រទី១៖** បន្តទប់ស្កាត់ការនាំចូលជំងឺកូវីដ-១៩ បំប្លែងថ្មីប្រភេទ Delta ដោយត្រូវអនុវត្តវិធានការសំខាន់ៗ ចំនួន ០៥ ដូចខាងក្រោម៖

១. ពង្រឹងការគ្រប់គ្រងការចេញចូលក្នុងប្រទេសទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ឱ្យបានហ្មត់ចត់បំផុត។ ក្នុងនោះ រាជរដ្ឋាភិបាល សម្រេចរៀបចំមណ្ឌលធ្វើចត្តាឡីស័កតាមព្រំដែន ដើម្បីទប់ស្កាត់ការនាំវីរុសបំប្លែងថ្មីចូលក្នុងសហគមន៍។

២. ធ្វើតេស្តរហ័សចំពោះអ្នកដំណើរចូលមកក្នុងប្រទេសទាំងអស់។

៣. ចាត់ចែងធ្វើចត្តាឡីស័កគ្រប់អ្នកដំណើរចូលប្រទេសឱ្យបានត្រឹមត្រូវ។

៤. ដាក់ឱ្យព្យាបាលដោយឡែកចំពោះអ្នកជំងឺកូវីដ-១៩ បំប្លែងថ្មីប្រភេទ Delta និងតម្រូវឱ្យធ្វើចត្តាឡីស័ករហូតដល់ ២១ថ្ងៃ។

៥. អប់រំណែនាំពលករកម្ពុជាឱ្យមានភាពនឹងនក្នុងការបន្តស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។ រាជរដ្ឋាភិបាលកម្ពុជា បានពិភាក្សាជាមួយរាជរដ្ឋាភិបាលថៃក្នុងការមើលថែទាំពលករកម្ពុជានៅប្រទេសថៃ ឱ្យដូចប្រជាជនថៃដែរ។

– **យុទ្ធសាស្ត្រទី២៖** ខិតខំកាត់បន្ថយទំហំភូមិសាស្ត្រនៃការឆ្លងជំងឺកូវីដ-១៩ និងចំនួននៃការឆ្លងជំងឺកូវីដ-១៩ ដោយត្រូវអនុវត្តវិធានការចំនួន ៤ គឺ៖ វិធានការអប់រំ វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់ឱ្យបានហ្មត់ចត់។

– **យុទ្ធសាស្ត្រទី៣៖** ខិតខំព្យាបាលអ្នកជំងឺកូវីដ-១៩ ឱ្យឆាប់បានជាសះស្បើយ និងកាត់បន្ថយចំនួនអ្នកស្លាប់ និងឈានទៅលុបបំបាត់ការស្លាប់ដោយជំងឺកូវីដ-១៩ ដោយត្រូវអនុវត្តវិធានការ ៥ ដូចខាងក្រោម៖

១. ស្វែងរកប្រភពថ្នាំព្យាបាលឱ្យបានច្បាស់លាស់ និងកំណត់ឱ្យបានច្បាស់លាស់នូវស្តង់ដារនៃការប្រើប្រាស់ថ្នាំព្យាបាលជំងឺកូវីដ-១៩។

២. រៀបចំមន្ទីរពេទ្យបន្ថែមតាមខេត្ត និងស្រុក ដោយត្រូវរៀបចំឱ្យមានបន្ទប់សង្គ្រោះបន្ទាន់ និងការបំពាក់សម្ភារឧបករណ៍សង្គ្រោះបន្ទាន់ រួមទាំងការបំពាក់សម្ភារឧបករណ៍សង្គ្រោះបន្ទាន់នៅតាមមន្ទីរពេទ្យយោធា តាមភូមិភាគនានា ។

៣. ហ្វឹកហ្វឺនគ្រូពេទ្យបន្ថែម ដើម្បីពង្រឹងសមត្ថភាពព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩។

៤. ខិតខំបញ្ជាទិញឧបករណ៍សម្ភារចាំបាច់ សម្រាប់ប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ឱ្យបានឆាប់។

៥. ការដាក់អ្នកជំងឺកូវីដ-១៩ ស្រាលៗ ឱ្យព្យាបាលតាមផ្ទះ ហើយរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ប្រចាំថ្ងៃមក **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

– **យុទ្ធសាស្ត្រទី៤៖** បង្កើនការរុករក និងគ្រប់គ្រងអ្នកវិជ្ជមានជំងឺកូវីដ-១៩ ដោយត្រូវអនុវត្តវិធានការ ៥ ដូចខាងក្រោម៖

១. រៀបចំតំបន់យកសំណាក ដើម្បីយកសំណាកទៅពិនិត្យរកអ្នកជំងឺកូវីដ-១៩។

២. ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ក្នុងការវិភាគរកវីរុសបំប្លែងថ្មីប្រភេទ Delta។

៣. ពង្រីកការធ្វើតេស្តរហ័ស ដោយពិចារណាអនុញ្ញាតឱ្យក្រុមហ៊ុនឯកជននានា ធ្វើតេស្តរហ័សដល់បុគ្គលិករបស់ខ្លួន។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានណែនាំឱ្យក្រសួងសុខាភិបាលផ្តល់ឧបករណ៍ធ្វើតេស្តរហ័សដល់កងទ័ព នគរបាល និងកងរាជអាវុធហត្ថ ដែលបំពេញការងារក្នុងអង្គភាពប្រតិបត្តិការ។

៤. គ្រប់គ្រងការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ។

៥. ពង្រីកការតាមដានការចម្លងជំងឺកូវីដ-១៩ ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា QR Code។

– **យុទ្ធសាស្ត្រទី៥៖** គ្រប់គ្រងចាត់ចែងសាកសពអ្នកស្លាប់ដោយជំងឺកូវីដ-១៩ ឱ្យបានត្រឹមត្រូវ ដោយត្រូវអនុវត្តវិធានការ ៣ ដូចខាងក្រោម៖

១. រៀបចំទីបញ្ចាសម្រាប់បូជាសពអ្នកស្លាប់ដោយជំងឺកូវីដ-១៩ ចំពោះកន្លែងដែលមិនទាន់បានរៀបចំ។ សហការជាមួយព្រះសង្ឃ គណៈកម្មការវត្ត ដើម្បីប្រើប្រាស់ទីបញ្ចាសម្រាប់បូជាសពនៅតាមវត្តមួយចំនួនជាបន្ថែមទៀតដើម្បីបូជាអ្នកស្លាប់ដោយជំងឺកូវីដ-១៩។

២. ស្វែងរកដីសម្រាប់បញ្ចុះសពរបស់ជនជាតិដែលស្លាប់ដោយជំងឺកូវីដ-១៩ តាមប្រពៃណីទំនៀមទម្លាប់របស់បងប្អូន។

៣. ផលិតក្តាមឈូសសម្រាប់អ្នកស្លាប់ដោយជំងឺកូវីដ-១៩ ដោយប្រើប្រាស់ឈើ ដែលរឹបអូសបានពីបទល្មើសព្រៃឈើ។ ចំពោះមុខនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ថវិកាដល់រាជធានីខេត្ត ដើម្បីទិញក្តាមឈូសដែលមានស្រាប់នៅតាមរាជធានី ខេត្តនីមួយៗ ត្រៀមទុកសម្រាប់ប្រើប្រាស់។

– **យុទ្ធសាស្ត្រទី៦៖** បន្តស្វះស្វែងរកវ៉ាក់សាំងចាក់ជូនប្រជាជនឱ្យបានគ្រប់ ១០លាននាក់ និងស្វះស្វែងរកវ៉ាក់សាំងដើម្បីចាក់ជូនក្មេងអាយុក្រោម ១៨ឆ្នាំ ដោយត្រូវអនុវត្តវិធានការ ៣ ដូចខាងក្រោម៖

១. រកវ៉ាក់សាំងឱ្យបានគ្រប់គ្រាន់ដើម្បីចាក់ជូនប្រជាជន ១០លាននាក់។

២. យកប្រទេសចិនជាបង្អែកសម្រាប់ផ្គត់ផ្គង់វ៉ាក់សាំង តាមផែនការ ១០លាននាក់ ឯវ៉ាក់សាំងពីប្រភពផ្សេងៗ គឺជាប្រភពគាំទ្រ។

៣. ប្រមូលផ្តុំផ្តល់វ៉ាក់សាំងដែលទទួលបានទៅតំបន់អាទិភាព និងត្រូវប្រមូលផ្តុំកម្លាំងដើម្បីបង្កើនល្បឿននៃការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ។ បន្ទាប់មកត្រូវស្វះស្វែងរកវ៉ាក់សាំងដើម្បីចាក់ជូនក្មេងក្រោមអាយុ ១៨ឆ្នាំ។

**បញ្ហាផ្សេងៗ៖ សម្តេចតេជោនាយករដ្ឋមន្ត្រី** បានណែនាំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ឱ្យពិនិត្យ និងកែសម្រួលឡើងវិញនូវនីតិវិធីនៃការប្រើប្រាស់ថវិកាសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលកន្លងមក មានប្រភពថវិកាពីសប្បុរសជន និងពីប្រភពថវិកាជាតិ។ ដោយសារថវិកាពីប្រភពសប្បុរសជនបានចំណាយជិតអស់ ហេតុនេះ ក្នុងពេលដ៏ខ្លីខាងមុខ នឹងត្រូវប្រើប្រាស់ថវិកាតែពីប្រភពថវិកាជាតិ ដែលចាំបាច់ ត្រូវរៀបចំនីតិវិធីប្រើប្រាស់ឱ្យបានឆាប់រហ័ស។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបជាសេចក្តីរាយការណ៍ តាមការគួរ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

ថ្ងៃព្រហស្បតិ៍ ៧ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១

**រដ្ឋលេខាធិការប្រចាំការ**

**សក់ សេដ្ឋា**

ស ខេង
05/07/21